រាជធានីភ្នំពេញ៖ ថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០១៥

# សេចក្តីប្រកាសព័ត៌មាន

# សិក្ខាសាលាផ្សព្វផ្សាយ ស្តីពី បញ្ជីគណនេយ្យសាមញ្ញ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

នាវេលាម៉ោង ៨:៣០នាទី ព្រឹក ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ នៅសណ្ឋាគារ អ៊ីនធើខនធើណិនថល ភ្នំពេញ (Inter_Continental Hotel) មានការរៀបចំ សិក្ខាសាលា ស្តីពីបញ្ជីគណនេយ្យសាមញ្ញ ដែលមានការសហការរៀបចំ ដោយ អគ្គនាយកដ្ឋានពន្ធដារ និង ទីភ្នាក់ងារ សហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ក្រោមអធិបតី-ភាពរបស់ ឯកឧត្តម **វ៉ាន់ ពុទ្ធិពល** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ និងមានការចូលរួម ពីសំណាក់លោកប្រធាន-អនុប្រធាននាយកដ្ឋាន លោកប្រធាន- អនុប្រធានសាខាពន្ធដារខណ្ឌទាំងអស់ មន្ត្រីនៃអគ្គនាយកដ្ឋានពន្ធដារ លោកអនុប្រធានតំណាង JICA ប្រចាំប្រទេសកម្ពុជា និងអ្នកជាប់ពន្ធ ស្ថិតក្រោមការគ្រប់គ្រងរបស់សាខាពន្ធដារ នៃរាជធានីភ្នំពេញ។


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

ជាកិច្ចចាប់ផ្តើម ឯកឧត្តម វ៉ាន់ ពុទ្ធិពល អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ បានសម្តែងនូវកិច្ចស្វាគមន៍ចំពោះ លោកអនុប្រធានតំណាង JICA ប្រចាំនៅកម្ពុជា មន្ត្រីរាជការពន្ធដារគ្រប់ជាន់ថ្នាក់ និងសិក្ខាកាម ដែលបានចូលរួមក្នុងសិក្ខាសាលានាថ្ងៃនេះ។ ឆ្លៀតក្នុងឱកាសនេះ ឯកឧត្តម វ៉ាន់ ពុទ្ធិពល ក៏បានលើកឡើងពីកម្មវិធីកំណែទម្រង់រដ្ឋបាលសារពើពន្ធ នៃព្រះរាជាណាចក្រកម្ពុជា ដែលបានលុបបំបាត់របបម៉ៅការ ដោយផ្ទេរអ្នកជាប់ពន្ធមករបបស្វ័យប្រកាស។ អ្នកជាប់ពន្ធរបបស្វ័យប្រកាសត្រូវបានបែងចែកជា ៣កំរិត (អ្នកជាប់ពន្ធតូច អ្នកជាប់ ពន្ធមធ្យម និងអ្នកជាប់-ពន្ធធំ)។ ជាមួយគ្នានេះដែរ ឯកឧត្តម ក៏បានបញ្ជាក់អំពីបញ្ជី គណនេយ្យសាមញ្ញ ដែលនឹងត្រូវដាក់អនុវត្តសម្រាប់អ្នកជាប់ពន្ធតូច ដែលតម្រូវឱ្យអ្នកជាប់ពន្ធកត់ត្រាការទិញ-លក់ ដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធដែលមានលក្ខណៈសាមញ្ញ និងមានភាពងាយស្រួល។ ជាងនេះទៅទៀត អគ្គនាយកដ្ឋានពន្ធដារ ក៏បានខិតខំប្រឹងប្រែងផងដែរ ក្នុងការជម្រុញឱ្យមានការបង់ពន្ធប្រកបដោយតម្លាភាព សមធម៌ និងភាពត្រឹមត្រូវ។

ជាកិច្ចបញ្ចប់ ឯកឧត្តម វ៉ាន់ ពុទ្ធិពល អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ បានសម្តែងនូវសេចក្តីថ្លែងអំណរគុណចំពោះលោកអនុប្រធានតំណាង JICA ប្រចាំប្រទេសកម្ពុជា លោកប្រធាន-អនុប្រធាននាយកដ្ឋាន លោកប្រធាន-អនុប្រធានសាខាពន្ធដារខណ្ឌ មន្ត្រីពន្ធដារ និងសិក្ខាកាមទាំងអស់ ដែលបានចូលរួមក្នុងសិក្ខាសាលានេះ។ ឯកឧត្តមបានបន្ថែមទៀតថា អគ្គនាយកដ្ឋានពន្ធដារនឹងខិតខំពង្រឹង ការអនុវត្តច្បាប់ បន្តកែលម្អការផ្តល់សេវាអ្នកជាប់ពន្ធ ឱ្យបានល្អប្រសើរ ប្រកបដោយប្រសិទ្ធិភាព និងភាពទន់ភ្លន់ ធ្វើយ៉ាងណាឱ្យអ្នកជាប់ពន្ធរីករាយក្នុងការសហការបង់ពន្ធជូនរដ្ឋ ដែលស្របតាមកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ និងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ របស់រាជរដ្ឋាភិបាល ៕



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ